ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

# បទបញ្ញត្តិនិងកម្រិតវិន័យ
# ចំពោះបេក្ខជនដែលបានប្រព្រឹត្តខុសឆ្គងនៅក្នុងការប្រឡងជ្រើសរើស
# ចូលក្របខ័ណ្ឌក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
# (សម័យប្រឡងថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០១៦)

ដើម្បីរក្សាសណ្តាប់ធ្នាប់របៀបរៀបរយក្នុងការប្រឡង និងយោងតាមសេចក្តីជូនដំណឹងលេខ៦៦២១ សជណ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០១១ និងលិខិតលេខ៦៤៦ សជណ ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១១ លេខ១០៥៤ សជណ ចុះថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១១ របស់ទីស្តីការគណៈរដ្ឋមន្ត្រី បេក្ខជនទាំងអស់ត្រូវគោរពតាមបទបញ្ញត្តិ នៃការប្រឡងដូចមានចែងតាមករណីខាងក្រោម។ ទន្ទឹមនេះដែរ បេក្ខជនត្រូវសហការគ្រប់ពេលវេលាជាមួយមន្ត្រីអង្គភាពប្រឆាំងអំពើពុករលួយ និងក្រុមជនបង្គោលប្រឆាំងអំពើពុករលួយ នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដើម្បីធ្វើឱ្យការប្រឡងនេះប្រព្រឹត្តទៅបានល្អតាមបទបញ្ញត្តិ និងកម្រិតវិន័យ ។

I. **បទបញ្ញត្តិទូទៅ:**

១. ប្រការដែលបេក្ខជនត្រូវអនុវត្ត:

- ត្រូវមកដល់មណ្ឌលប្រឡងឱ្យបានមុនដំណើរការប្រឡង
- ត្រូវស្លៀកពាក់សមរម្យ
- ត្រូវយកមកជាមួយនូវបង្កាន់ដៃទទួលពាក្យ និងសលាកប័ត្រឯកត្តជន បង្ហាញអនុរក្ស
- ត្រូវអនុញ្ញាតតាមការណែនាំរបស់គណៈមេប្រយោគ និងអ្នកមានសមត្ថកិច្ចថែរក្សាសណ្តាប់ធ្នាប់ ក្នុងការស្រាវជ្រាវរកឯកសារ សំណៅសម្ភារផ្សេងៗ ដែលក្រសួងមិនអនុញ្ញាតឱ្យយកចូលក្នុងមណ្ឌលប្រឡង ឬបន្ទប់ប្រឡង
- ត្រូវគោរពតាមការណែនាំរបស់អនុរក្ស ដូចជាអង្គុយចំលេខតុដែលអនុរក្សបានបង្ហាញ
- បំពេញលើក្បាលសន្លឹកកិច្ចការប្រឡងដែលអនុរក្សចែកឱ្យ
- ប្រគល់សន្លឹកកិច្ចការជូនអនុរក្សវិញពេលដល់ម៉ោង ទោះកិច្ចការនោះបានធ្វើ ឬពុំបានធ្វើក៏ដោយ
- ត្រូវរក្សាសណ្តាប់ធ្នាប់របៀបរៀបរយនៃការប្រឡង និងគោរពឱ្យបានត្រឹមត្រូវនូវបទបញ្ញត្តិ នៃការប្រឡង។

២. ប្រការដែលបេក្ខជនមិនត្រូវអនុវត្ត:

- មិនត្រូវមកដល់មណ្ឌលប្រឡងក្រោយការចាប់ផ្តើមធ្វើវិញ្ញាសាឡើយ
- មិនត្រូវយកចូលមណ្ឌលប្រឡង ឬបន្ទប់ប្រឡង នូវអាវុធជាតិផ្ទុះ ទូរស័ព្ទ អាយកូម និងឧបករណ៍អេឡិចត្រូនិចគ្រប់ប្រភេទ សៀវភៅ ឯកសារ សំណៅ ក្រដាសព្រាង ប៊ិច ខ្មៅដៃ ជ័រលុប ទឹកលុប កាតាប ចង់ សំពៀត កញ្ចប់ផ្សេងៗ
- មិនត្រូវចូលក្នុងបន្ទប់ប្រឡង មុនពេលអនុរក្សហៅឈ្មោះ
- មិនត្រូវបដិសេធ ឬប្រឆាំងតបតបង្កបាតុភាពដោយពាក្យសំដី ឬដោយកាយវិការចំពោះអ្នកមានសមត្ថកិច្ចត្រួតពិនិត្យ ឬមេប្រយោគ ក្នុងការត្រួតពិនិត្យស្រាវជ្រាវរកឯកសារ សំណៅ សម្ភារផ្សេងៗ ដែលត្រូវហាមឃាត់មិនឱ្យយកចូលមណ្ឌលប្រឡង ឬបន្ទប់ប្រឡង
- មិនត្រូវធ្វើចម្លើយនៅលើសន្លឹកកិច្ចការណា ដែលគ្មានហត្ថលេខារបស់អនុរក្ស
- មិនត្រូវចម្លងប្រធានវិញ្ញាសាចូលក្នុងសន្លឹកកិច្ចការ ឬក្រដាសដទៃ និងមិនត្រូវបោះប្រធានវិញ្ញាសាចេញទៅក្រៅបន្ទប់ប្រឡងឡើយ

- មិនត្រូវងើបឈរ ងាកឆ្វេង ងាកស្តាំ អើតឈ្ងោកទៅមុខ បែរទៅក្រោយ ឬដើរចេញពីកន្លែង ដោយគ្មានការអនុញ្ញាតពីអនុរក្ស និងមិនត្រូវសរសេរកិច្ចការហើយអានខ្លាំងៗ ឮដល់អ្នកជិតខាង ឬឆក់អូសទាញយកសន្លឹកកិច្ចការរបស់អ្នកដទៃមកដាក់ពីមុខ ឬដាក់ពីក្រោមសន្លឹកកិច្ចការរបស់ខ្លួនឡើយ
- មិនត្រូវប្តូរសន្លឹកកិច្ចការ ឬក្រដាសព្រាង ឬផ្ទៀងផ្ទាត់ចម្លើយ ឬចម្លងគ្នា និងមិនត្រូវដាក់សន្លឹកកិច្ចការឆ្ងាយពីមុខរបស់ខ្លួន បង្កឱ្យអ្នកដទៃមើល ឬអូសឆក់យកបាន
- មិនត្រូវធ្វើសញ្ញាសម្គាល់លើសន្លឹកកិច្ចការដូចជា សរសេរអក្សរប្លែងពីតួអក្សរទាំងអស់ក្នុងកិច្ចការ ធ្វើសញ្ញាផ្សេងៗ ឬគូសបន្ទាត់ខុសប្រក្រតី ឬលុបទឹកស និងមិនត្រូវសរសេរទឹកប៊ិចខុសពណ៌គ្នា លើសន្លឹកកិច្ចការនៃវិញ្ញាសាតែមួយឡើយ។ ក្នុងករណីអស់ទឹកប៊ិច ហើយត្រូវប្រើទឹកប៊ិចថ្មីមកសរសេរបន្តនោះ បេក្ខជនត្រូវសុំការអនុញ្ញាតពីអនុរក្ស
- មិនត្រូវលាក់ ឬហែកសន្លឹកកិច្ចការរបស់ខ្លួន និងមិនត្រូវហែក ឬលាក់សន្លឹកកិច្ចការអ្នកដទៃ
- មិនត្រូវបំផ្លាញ ឬធ្វើឱ្យខូចខាតសម្ភារនៅក្នុងបន្ទប់ប្រឡងដូចជា ដោះទ្វារបង្អួច ធ្វើឱ្យរបើកជញ្ជាំង ក្តារ បាក់បែកតុ ជើងម៉ា ឬក្តារខៀនជាដើម
- មិនត្រូវឱ្យអ្នកដទៃមកប្រឡងជំនួស ឬមកប្រឡងជួយឡើយ
- មិនត្រូវប្រើពាក្យសំដី និងអាកប្បកិរិយា ដែលនាំឱ្យខូចសណ្តាប់ធ្នាប់ របៀបរៀបរយនៃការប្រឡង និងប៉ះពាល់ដល់កិត្តិយសរបស់មេប្រយោគ
- មិនអនុញ្ញាតឱ្យសរសេរទឹកប៊ិចអ្វីផ្សេងៗក្រៅពីទឹកប៊ិចពណ៌ខៀវឡើយ។

II. <u>បទបញ្ញត្តិ និងកម្រិតវិន័យ ចំពោះបេក្ខជនលួចចម្លង:</u>

១.<u>បទប្បញ្ញត្តិ:</u>

ត្រូវបានកំណត់ថា ការលួចចម្លង នូវសកម្មភាពទាំងឡាយណា ដូចខាងក្រោម:
- ចម្លងពីសៀវភៅ សំណៅឯកសារ ឬពីសំណៅចម្លើយរបស់អ្នកដទៃ
- ចម្លងកិច្ចការរបស់អ្នកដទៃ ឬយកកិច្ចការអ្នកដទៃមកដាក់នៅកន្លែងដែលខ្លួនអង្គុយ
- អើតមើលកិច្ចការរបស់អ្នកដទៃ
- អង្គុយខុសពីលេខតុរបស់ខ្លួន ដោយគ្មានការអនុញ្ញាតពីអនុរក្ស
- បង្កឱ្យអ្នកដទៃចម្លង
- ប្តូរសន្លឹកកិច្ចការគ្នា ឬប្តូរក្រដាសព្រាងគ្នា ផ្ទៀងផ្ទាត់ចម្លើយគ្នា ឬចម្លងគ្នាជាក់ស្តែង។

២.<u>កម្រិតវិន័យ:</u>

រាល់បំណងលួចចម្លងត្រូវទទួលការព្រមានពីអនុរក្ស។ ក្រោយពីទទួលការព្រមាន និងការដកហូតឯកសារ ឬការហាមប្រាមពីអនុរក្សមួយដងហើយៗ បេក្ខជននៅតែបន្តលួចចម្លងទៀត បេក្ខជនទាំងនោះត្រូវបានពិន្ទុសូន្យ។

III. <u>បទបញ្ញត្តិ និងកម្រិតវិន័យ ចំពោះបេក្ខជនប្រឡងជំនួសនិងប្រឡងជួយ បេក្ខជនដែលធ្វើឱ្យខូចសណ្តាប់ធ្នាប់ របៀបរៀបរយ នៃការប្រឡង និងប៉ះពាល់ដល់កិត្តិយសមេប្រយោគ:</u>

១. មិនអនុញ្ញាតឱ្យចូលប្រឡងវិញ្ញាសាណាមួយ ចំពោះបេក្ខជនដែលមកដល់បន្ទប់ប្រឡង ក្រោយការចាប់ផ្តើមវិញ្ញាសានោះ យ៉ាងយូរ ១៥នាទី។ អាចឱ្យចូលប្រឡងបានលុះត្រាណាមានការអនុញ្ញាតពីប្រធានគណៈមេប្រយោគ។

២. ត្រូវបានកំណត់ពិន្ទុសូន្យលើមុខវិជ្ជាណាមួយ ចំពោះបេក្ខជនមានសកម្មភាព ដូចខាងក្រោម:
- ដើរចុះដើរឡើង ចេញពីកន្លែងអង្គុយ ដោយគ្មានការអនុញ្ញាតពីអនុរក្ស
- ហែកសន្លឹកកិច្ចការ ឬមិនព្រមប្រគល់សន្លឹកកិច្ចការជូនអនុរក្ស
- ផ្លាស់កន្លែងអង្គុយ លុបលេខតុពីកន្លែងដែលបានកំណត់ ទៅសរសេរលេខតុរបស់ខ្លួននៅកន្លែងផ្សេង
- ឱ្យសន្លឹកកិច្ចការ ឬសំណៅក្រដាសព្រាងរបស់ខ្លួនទៅអ្នកដទៃចម្លង

- ឱ្យអ្នកដទៃសរសេរលើសន្លឹកកិច្ចការរបស់ខ្លួន
- សរសេរលើសន្លឹកកិច្ចការរបស់អ្នកដទៃ។

៣. ត្រូវបានកំណត់ថា ឱ្យធ្លាក់ និងផ្អាកមិនឱ្យប្រឡងមួយឆ្នាំបន្ទាប់ ចំពោះបេក្ខជនដែលមានសកម្មភាព ដូចខាងក្រោម:
- បោះប្រធានវិញ្ញាសាចេញក្រៅបន្ទប់ប្រឡង ឬចេញទៅយកឯកសារ ឬសំណៅចម្លើយ ពាក់ព័ន្ធនឹងប្រធានវិញ្ញាសា ចូលមកក្នុងបន្ទប់ប្រឡងវិញក្នុងពេលធ្វើវិញ្ញាសា
- បង្កជម្លោះនៅក្នុងបន្ទប់ប្រឡង ដោយគំរាមកំហែងលើបេក្ខជនដទៃ
- ដណ្តើមយកសន្លឹកកិច្ចការរបស់អ្នកដទៃមកចម្លង
- ហែក ឬលាក់សន្លឹកកិច្ចការអ្នកដទៃ
- យកសន្លឹកកិច្ចការអ្នកដទៃ មកធ្វើសន្លឹកកិច្ចការរបស់ខ្លួន។

៤. ត្រូវបានកំណត់ឱ្យធ្លាក់ និងផ្អាកមិនឱ្យប្រឡងពីរឆ្នាំបន្តបន្ទាប់ ចំពោះបេក្ខជនដែលមានសកម្មភាព ដូចខាងក្រោម:
- លាក់អាវុធ ជាតិផ្ទុះ ទូរស័ព្ទ អាយកូម និងឧបករណ៍អេឡិចត្រូនិចគ្រប់ប្រភេទក្នុងបន្ទប់ប្រឡង
- ឱ្យអ្នកដទៃមកប្រឡងជំនួស
- ធ្វើឱ្យខូចសម្ភារក្នុងបន្ទប់ប្រឡង និងខូចខាតបន្ទប់ប្រឡងដោយចេតនា
- មិនអនុវត្តតាមការណែនាំរបស់មេប្រយោគ ឬអ្នកមានសមត្ថកិច្ចក្នុងមណ្ឌលប្រឡង ដោយបង្កបាតុភាពជាពាក្យសំដី ជាកាយវិការ ធ្វើឱ្យប៉ះពាល់ដល់កិត្តិយស ឬរាងកាយមេប្រយោគ ឬអ្នកមានសមត្ថកិច្ចត្រួតពិនិត្យការប្រឡង។ ក្នុងករណីចាំបាច់ ត្រូវបញ្ជូនបេក្ខជនដែលមានកំហុសនោះ ទៅស្ថាប័នមានសមត្ថកិច្ចដើម្បីដោះស្រាយតាមច្បាប់ជាធរមាន។

៥. បេក្ខជនដែលបានបន្លំប្រឡង ហើយធ្វើសកម្មភាពជំនួសអ្នកដទៃ ឬមកប្រឡងធ្វើសកម្មភាពជួយអ្នកដទៃ ត្រូវបានគណៈកម្មការប្រឡងចាប់កំហុសជាក់ស្តែង បេក្ខជនប្រឡងជំនួសគេ ឬប្រឡងជួយគេនោះ ត្រូវបានពិន្ទុសូន្យលើមុខវិជ្ជានោះ។ ចំពោះបេក្ខជនដែលត្រូវគេជួយ ក៏ត្រូវបានពិន្ទុសូន្យលើមុខវិជ្ជានោះដែរ។

៦. បេក្ខជនដែលបានពិន្ទុ (0) លើមុខវិជ្ជាណាមួយហើយ ត្រូវចាត់ទុកថាប្រឡងធ្លាក់។

ចំពោះកំហុសក្រៅពីករណីខាងលើ កម្រិតវិន័យ ត្រូវបានកំណត់ដោយប្រធានគណៈមេប្រយោគ។

រាជធានីភ្នំពេញ ថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០១៦

**ប្រធានគណៈកម្មការប្រឡង**

**យុទ្ធ ភូថង**